01227002

E397/1

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 25 / 04 / 2016
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: [signature]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង

សាធារណៈ / Public

ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៦

**ជូនចំពោះ៖** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងការតំណាងពីមុនឲ្យសាក្សីពីសំណាក់មេធាវីការពារក្តីជាតិ គង់ សំអុន

១. អង្គជំនុំជម្រះទទួលបានសំណើរបស់សហព្រះរាជអាជ្ញាដែលបានដាក់នៅថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ទាក់ទិននឹងការតំណាងពីមុនឲ្យសាក្សីនៅក្នុងសំណុំរឿងផ្សេងរបស់លោក គង់ សំអុន ដែលជាមេធាវីការពារក្តីជាតិបច្ចុប្បន្នរបស់ជនជាប់ចោទ ខៀវ សំផន ("សំណើសុំឯកសារ E397)។ សហព្រះរាជអាជ្ញា អះអាងថា ពុំមានទំនាស់ផលប្រយោជន៍កើតឡើងដល់កម្រិតមួយដែលលោក គង់ សំអុន គួរត្រូវបានដកហូតចេញពីមេធាវីការពារក្តីជាតិរបស់ ខៀវ សំផន ឡើយ ប៉ុន្តែផ្ទុយទៅវិញ "វាសំខាន់គ្រប់គ្រាន់នឹងតម្រូវឲ្យមានការធានានូវសុវត្ថិភាពបន្ថែមទៀត"។ សហព្រះរាជអាជ្ញាអះអាងថា មានហានិភ័យមួយចំនួនដែលកើតចេញពីការតំណាងកាលពីពេលមុនរបស់លោក គង់ សំអុន ឲ្យសាក្សីសាក្សី 2-TCW-898, 2-TCW-931, 2-TCW-906 និង 2-TCW-816 នៅក្នុងសំណុំរឿង ០០១ ហើយថា វានៅតែមានការ

បង្ហាញឱ្យឃើញនូវទំនាស់ដែលអាចធ្វើឱ្យប៉ះពាល់ដល់សុចរិតភាពនៃកិច្ចដំណើរការនីតិវិធី បើទោះបីជាហានិភ័យទាំងនោះ មិនបានកើតឡើងក៏ដោយ។ សហព្រះរាជអាជ្ញាបានស្នើសុំឱ្យអង្គជំនុំជម្រះបង្គាប់ឱ្យមេធាវីការពារក្តី ខៀវ សំផន ស្នើសុំពី ខៀវ សំផន នូវការលះបង់សិទ្ធិមួយជាលាយលក្ខណ៍អក្សរ និង បង្គាប់ឱ្យតែមេធាវីការពារក្តីអន្តរជាតិ Anta Guissé ម្នាក់ប៉ុណ្ណោះ ជាអ្នកដេញដោលសាក្សីទាំងនេះ (សំណើសុំ កថាខណ្ឌ ៦-៨)។

២. នៅក្នុងសវនាការថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៦ ភាគីបានធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ដើម្បីឆ្លើយតប។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និង មេធាវីការពារក្តី នួន ជា ពុំបានលើកឡើងនូវការព្រួយបារម្ភនានាអំពីទំនាស់ផលប្រយោជន៍ដែលអាចមានទេ ហើយថាជាឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះក្នុងការសម្រេចលើបញ្ហានេះ។ មេធាវីជាតិការពារក្តី ខៀវ សំផន លើកឡើងថា ពុំមានទំនាស់ផលប្រយោជន៍កើតមាន ដោយសារតែគាត់ធ្លាប់បំពេញមុខងារជាមេធាវីប្រឹក្សាសម្រាប់សាក្សី 2-TCW-898, 2-TCW-931, 2-TCW-906 និង 2-TCW-816 ក្នុងសំណុំរឿង ០០១ នោះឡើយ។ មេធាវីជាតិកត់សម្គាល់ថា ពុំមានទំនាក់ទំនងរវាងកូនក្តីគាត់ និង សាក្សីទាំងនេះទេ ដោយសារសាក្សីទាំងនេះពុំបានធ្វើការចោទប្រកាន់លើអង្គហេតុដែលថា ខៀវ សំផន គឺជាថ្នាក់លើរបស់ពួកគេ ឬថា ពួកគេមានទំនាក់ទំនងផ្សេងទៀតជាមួយជនជាប់ចោទ។ មេធាវីការពារក្តី គង់ សំអុន បានកត់សម្គាល់បន្ថែមទៀតថា គាត់ពុំបានទាក់ទងជាមួយសាក្សីទាំងនេះទេ ចាប់តាំងពីឆ្នាំ ២០០៩ មក ហើយគាត់ពុំមានឱកាសក្នុងការប្រើឥទ្ធិពលទៅលើពួកទេចាប់តាំងពីពេលនោះមក។ គាត់លើកឡើងថា សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យ ខៀវ សំផន លះបង់សិទ្ធិការពារក្តីដោយមេធាវីរូបនេះជាលាយលក្ខណ៍អក្សរពុំមានភាពចាំបាច់ទេ ដោយសារថា ខៀវ សំផន បានដឹងពីតួនាទីពីមុនរបស់មេធាវីការពារក្តីរបស់គាត់ថា ជាមេធាវីប្រឹក្សារបស់សាក្សីទាំងនេះ រួចហើយ មុនពេលមកការពារក្តីឱ្យរូបគាត់។ ចុងក្រោយ គាត់លើកឡើងថា ដូចដែលមេធាវីការពារក្តី ខៀវ សំផន បានបញ្ជាក់សាជាថ្មីនៅក្នុងសារអេឡិចត្រូនិករបស់ខ្លួននៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៦ និង ដោយសារអេឡិចត្រូនិករបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៦ រួចមកហើយគឺថា គាត់នៅមានកាតព្វកិច្ចរក្សាការសម្ងាត់នៅឡើយ (សេចក្តីព្រាងប្រតិចារឹកសវនាការជាភាសាអង់គ្លេស ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៦ ទំព័រ ៦៧-៨៣)។

៣. សាក្សី 2-TCW-898, 2-TCW-931, 2-TCW-906 និង 2-TCW-816 ដែលអង្គជំនុំជម្រះបានកំណត់ពេលមកផ្ដល់សក្ខីកម្មនាពេលដ៏ខ្លីខាងមុខ ធ្លាប់ត្រូវបានលោក គង់ សំអុន ធ្វើជាមេធាវីប្រឹក្សា នៅពេលពួកគេបានមកផ្ដល់សក្ខីកម្មនៅក្នុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០១។ នាពេលនោះ លោក គង់ សំអុន ត្រូវបានចាត់តាំងជាមេធាវីប្រឹក្សាសម្រាប់ពួកគេ ដើម្បីធានាថា សិទ្ធិរបស់ពួកគាត់មិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង ត្រូវបានការពារ។ អង្គជំនុំជម្រះសូមរម្លឹកថា បន្ទាប់ពីមានសារអេឡិចត្រូនិកមួយនៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៦ ដែលបានធ្វើដោយក្រុមមេធាវីការពារក្ដី ខៀវ សំផន អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីតាមរយៈសារ-អេឡិចត្រូនិកនៅថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៦ ថា អង្គជំនុំជម្រះនឹងតម្រូវឱ្យអង្គភាពគាំពារសាក្សី និង អ្នកជំនាញ (WESU) ទាក់ទងទៅសាក្សីទាំងនេះ ដើម្បីជូនដំណឹងថា នាពេលនេះមេធាវី គង់ សំអុន ក្លាយជាមេធាវីជាតិការពារក្ដី ខៀវ សំផន ហើយឱ្យអង្គភាពនេះបញ្ជាក់សាជាថ្មីដល់សាក្សីថា មេធាវីរូបនេះជាប់កាតព្វកិច្ចរក្សាការសម្ងាត់ និង ចុងក្រោយឱ្យសាកសួរសាក្សីទាំងនេះថាតើ ពួកគេមានបញ្ហាអ្វីត្រូវលើកឡើងដែរ ឬទេ ពាក់ព័ន្ធនឹងការសួរដេញដោលរបស់មេធាវីរូបនេះដល់ពួកគេនៅក្នុងពេលសវនាការ។ អង្គភាពគាំពារសាក្សី និងអ្នកជំនាញបានជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូងថា អង្គភាពគាំពារសាក្សី និង អ្នក-ជំនាញបានទាក់ទងសាក្សីទាំងនេះតាមពេលកំណត់ ហើយថា ទោះបីពុំមានការជំទាស់ពីសាក្សី 2-TCW-898, 2-TCW-931, 2-TCW-906 ទៅនឹងការសួរដេញដោលរបស់លោក គង់ សំអុន ក៏ដោយ តែសាក្សី 2-TCW-816 ចង់ឱ្យមេធាវី Anta Guissé តែម្នាក់គត់ដែលសួរសួរដេញដោលរូបគាត់ (សារអេឡិចត្រូនិកថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៦ សារអេឡិចត្រូនិកថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១៦)។

៤. អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា ការពិភាក្សាពេញលេញអំពីបញ្ហាអង្គច្បាប់ដែលកើតចេញពីការធ្វើជាមេធាវីប្រឹក្សាពីពេលមុនរបស់លោក គង់ សំអុន ត្រូវបានធ្វើឡើងក្នុងអំឡុងពេលសវនាការកាលពីថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៦ ដោយមានវត្តមានរបស់ ខៀវ សំផន និង មេធាវីរបស់គាត់ទាំងពីរ ដោយជនជាប់ចោទមិនបានលើកការជំទាស់ ឬ សួរសំណួរអ្វីឡើយ។ ផ្ទុយទៅវិញ មេធាវីការពារក្ដី ខៀវ សំផន បានបញ្ជាក់ថា កូនក្ដីរបស់ពួកគាត់បានដឹងច្បាស់អំពីស្ថានភាពនេះ ហើយមានការទុកចិត្តទាំងស្រុងទៅលើវិជ្ជាជីវៈនៃអ្នកតំណាងផ្លូវច្បាប់របស់គាត់។ ដោយកត់សំគាល់ថា នេះគឺជាបញ្ហាមួយដែលអាចធ្វើការជំទាស់ភ្លាមៗបាន

ហើយដោយ ខៀវ សំផន មិនបានលើកឡើងនៅពេលពិភាក្សានោះ អង្គជំនុំជម្រះយល់ថា មិនចាំបាច់មានការបោះបង់សិទ្ធិជាលាយលក្ខណ៍អក្សរទេ។

៥. អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា បើទោះជាតួនាទីពីមុនរបស់លោក គង់ សំអុន ជាមេធាវីប្រឹក្សារបស់សាក្សី 2-TCW-898, 2-TCW-931, 2-TCW-906 និង 2-TCW-816 និង តួនាទីបច្ចុប្បន្នរបស់គាត់ជាមេធាវីជាតិរបស់ជនជាប់ចោទ ខៀវ សំផន អាចមិនត្រូវបានចាត់ទុកថា ជាទំនាស់ផលប្រយោជន៍ដែលតម្រូវឱ្យមានវិធានការតឹងរ៉ឹងក្តី ស្ថានភាពដែលបានលើកឡើងនេះអាចធ្វើឱ្យសាធារណជនមានការយល់ច្រឡំ។ លើសពីនេះទៀត ដោយសារតែមានការជំទាស់របស់សាក្សី 2-TCW-816 អង្គជំនុំជម្រះសាលាដំបូង ស្របទៅនឹងជំហររបស់អង្គជំនុំជម្រះដែលបានផ្តល់ដំណឹងទៅភាគីតាមរយៈអ៊ីម៉ែល កាលពីថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៦ ទទួលយកសំណើរបស់មេធាវីការពារក្តី ខៀវ សំផន ហើយយល់ថា មានតែមេធាវីអន្តរជាតិ Anta Guissé ម្នាក់គត់ដែលត្រូវទទួលខុសត្រូវក្នុងការសួរដេញដោលសាក្សីរូបនេះ។ ទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះយល់ឃើញថា ដើម្បីរក្សាសុចរិតភាពនៃកិច្ចដំណើរការនីតិវិធីនោះ ជាការសមស្របដែលមេធាវី គង់ សំអុន មិនសួរដេញដោលសាក្សីទាំងអស់នេះ ជំនួសមុខឱ្យកូនក្តីបច្ចុប្បន្នរបស់គាត់។

៦. អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូង៖

ក/ បដិសេធសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យមានការលះបង់សិទ្ធិជាលាយលក្ខណ៍អក្សរពីជនជាប់ចោទ ខៀវ សំផន អំពីទំនាស់ផលប្រយោជន៍ណាមួយដែលអាចមាននាពេលអនាគត។

ខ/ ណែនាំឱ្យមេធាវីអន្តរជាតិ Anta Guissé សួរដេញដោលទៅលើសាក្សីទាំងបួនរូប (2-TCW-898, 2-TCW-931, 2-TCW-906 និង 2-TCW-816) តែម្នាក់ឯង។ និង

គ/ រម្លឹកថា មេធាវីជាតិ គង់ សំអុន ជាប់កាតព្វកិច្ចក្នុងការរក្សាការសម្ងាត់។

៧. ឯកសារនេះគឺជាការឆ្លើយតបជាផ្លូវការរបស់អង្គជំនុំជម្រះចំពោះឯកសារ E397។